**ខ្លឹមសារស្ដីពីជំនួបសម្ដែងការគួរសមរបស់ឯកឧត្តម Flavio Bonetti តំណាងអង្គការយូណេស្កូតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន**

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ – នៅរសៀលថ្ងៃទី២១ ខែមករា ឆ្នាំ២០២៦ នៅទីស្ដីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ) **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានទទួលជំនួបសម្ដែងការគួរសមជាមួយ **ឯកឧត្តម** Flavio Bonetti តំណាងអង្គការយូណេស្កូតែងតាំងថ្មី ក្នុងឱកាសប្រគល់លិខិតសារតាំងរបស់ឯកឧត្តម។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍យ៉ាងកក់ក្ដៅ និងអបអរសាទរ **ឯកឧត្តម** Flavio Bonetti ដែលត្រូវបានតែងតាំងជាតំណាងរបស់អង្គការយូណេស្កូ ប្រចាំនៅកម្ពុជា និងបានកត់សម្គាល់ថា វត្តមានរបស់ **ឯកឧត្តម** ឆ្លុះបញ្ចាំងពីតម្លៃដែលកម្ពុជាផ្ដល់លើភាពជាដៃគូយូរអង្វែងជាមួយអង្គការយូណេស្កូ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសម្ដែងនូវអំណរគុណដល់អង្គការយូណេស្កូ ចំពោះកិច្ចខិតខំប្រឹងប្រែង និងការបន្តគាំទ្រកម្ពុជា ជាពិសេស ក្នុងការជំរុញអាទិភាពអភិវឌ្ឍន៍របស់កម្ពុជា លើវិស័យអប់រំ វប្បធម៌ វិទ្យាសាស្ត្រ នវានុវត្តន៍ បរិស្ថាន និងការអភិរក្សសម្បត្តិបេតិកភណ្ឌ។

ទន្ទឹមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារៈសំខាន់នៃជំនួយបច្ចេកទេសរបស់អង្គការយូណេស្កូ ក្នុងការការពារប្រាសាទព្រះវិហារ ដែលជាសម្បត្តិបេតិកភណ្ឌពិភពលោក និងដែលបានទទួលរងផលប៉ះពាល់ដោយសារជម្លោះព្រំដែនកម្ពុជា-ថៃ នាពេលថ្មីៗនេះ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថា គ្មានប្រទេសណាមួយស្គាល់ច្បាស់អំពីតម្លៃនៃសន្តិភាពជាងប្រទេសកម្ពុជានោះទេ ដោយសារកម្ពុជាបានឆ្លងកាត់ភ្លើងសង្គ្រាម និងរបបប្រល័យពូជសាសន៍អស់ជាច្រើនឆ្នាំ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ជាថ្មីនូវការប្ដេជ្ញាចិត្តដ៏មោះមុតរបស់កម្ពុជា ក្នុងការបន្តពង្រឹងភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអង្គការយូណេស្កូ នាពេលខាងមុខ។

ដោយឡែក **ឯកឧត្តម** Flavio Bonetti បានសម្ដែងនូវសេចក្ដីសោមនស្សរីករាយដែលត្រូវបានចាត់ឱ្យមកបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជា និងបានលើកឡើងពីការប្ដេជ្ញាចិត្តដ៏មោះមុតរបស់ **ឯកឧត្តម** ក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងការបន្តខិតខំប្រឹងប្រែងចូលរួមក្នុងកិច្ចអភិរក្សបេតិកភណ្ឌ និងវិស័យពាក់ព័ន្ធនានា ដូចជាវិស័យអប់រំ បរិស្ថាន វិទ្យាសាស្ត្រ នវានុវត្តន៍ ព្រមទាំងការលើកកម្ពស់សន្តិភាពនិងការអភិវឌ្ឍប្រកបដោយចីរភាព។

ជាទីបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីអំពីការត្រៀមលក្ខណៈសម្របសម្រួល និងផ្ដល់កិច្ចសហប្រតិបត្តិការរបស់ កបទ.សអ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជានានូវជោគជ័យនៃបេសកកម្មរបស់ **ឯកឧត្តម** Flavio Bonetti នៅកម្ពុជា។

* * * * * * * * *